ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ......១៣....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តួនាទី និង ចំនានុក្រមអភិបាល អភិបាលរងខេត្ត ក្រុង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា១ .–

ខេត្ត ក្រុង ជាថ្នាក់រដ្ឋបាល ចំណុះរាជរដ្ឋាភិបាល មានវិសាលភាព និង សមត្ថកិច្ចគ្រប់គ្រងលើវិស័យរដ្ឋបាល និង នយោបាយ ដើម្បីធានា ថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ សិទ្ធិសេរីភាពរបស់ប្រជារាស្ត្រ លើកតម្កើងគុណជីវភាពរស់នៅ និង អភិវឌ្ឍន៍លើគ្រប់វិស័យ ។

អភិបាលខេត្ត ក្រុង ជាតំណាងរាជរដ្ឋាភិបាល និង តំណាងក្រសួង ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ក្នុងមណ្ឌលដែនដីរបស់ខ្លួន។

ខេត្ត ក្រុងនីមួយៗ ត្រូវដឹកនាំដោយអភិបាលខេត្ត ក្រុងមួយរូប ដោយមានអភិបាលរងទី១ មួយរូប និង អភិបាលរងមួយចំនួនទៀត ជាជំនួយការ។

អភិបាល អភិបាលរងទី១ និង អភិបាលរងខេត្ត ក្រុង ត្រូវស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងមហាផ្ទៃ។

**មាត្រា២ .-**

តួនាទី ភារកិច្ច របៀបរបបធ្វើការងារ របស់អភិបាល អភិបាលរងទី១ និង អភិបាលរងខេត្ត ក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

( ដើម្បីជូនជ្រាប )

-ដូចមាត្រា៤

( ដើម្បីអនុវត្ត )

-ឯកសារ កាលប្បវត្តិ